22/6

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ២០៦
ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩
សាលដីកា
លេខ៖ ២២៦
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៨០"ខ" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២០៦ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់តុលាការកំពូល។

<u>ត្រូវចោទពីបទ</u>៖ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦, ៥៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង ច្បាប់ព្រហ្មទណ្ឌអន្តរកាល។

១-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ១០ឌ ផ្លូវ២២៧ ក្រុមទី១០ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ នៅលីវ ឪពុកឈ្មោ[redacted]ាយឈ្មោ[redacted]ាសពីមុន ធ្លាប់ជាប់គុក ឃុំខ្លួនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១ ។

២-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរតំម៉ូតូ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ៣៩ ផ្លូវលំ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ ប្រពន្ធឈ្មោះនិន វ៉ាន់ថេត កូន០១នាក់ ឪពុកឈ្មោ[redacted] ម្តាយឈ្មោះ[redacted] ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥ បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១ ។

-មានមេធាវីលោក[redacted]



Scanned by CamScanner

៣-ជនជាប់ចោទឈ្មោះ: [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីលំនៅមុន ពេលចាប់ខ្លួនភូមិបឹងកុក ឃុំបឹងកុក ស្រុកទំរូមខេត្ត ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted]ាយឈ្មោះ: [redacted]នៅលីវ ចាប់ខ្លួនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ ឃុំខ្លួនថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៥ បច្ចុប្បន្ននៅ ពន្ធនាគារព្រៃស ម១ ។

៤-ជនជាប់ចោទឈ្មោះ: [redacted]ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ២៤ ផ្លូវលំ ភូមិថ្មគោល (គោកបញ្ជាប់) សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ នៅលីវ ឪពុកឈ្មោះ[redacted]ាយឈ្មោះ[redacted] (វ) បច្ចុប្បន្ននៅពន្ធនាគារព្រៃស ម១ ។

-មានមេធាវីលោក[redacted]

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ "ជាម្ចាស់បណ្តឹងសាទុក្ខ"

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ វេលាម៉ោង១៣ និង៣០នាទី មានករណីប្លន់ (ម៉ូតូ) ម៉ាកសេ១២៥ ពណ៌ខ្មៅ ស៊េរី២០០៣ បិតតែមស៊េរី២០០៤ នៅម្តុំវត្តដំបូកខ្ពស់ ផ្លូវលំ ក្រុម១០ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ជនរងគ្រោះក្នុងករណីប្លន់នេះមានឈ្មោះ[redacted] ភេទស្រី អាយុ៣១ឆ្នាំ រស់នៅផ្ទះលេខ៨ ផ្លូវ៤៨៤ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ នៅពេលដែលជនរងគ្រោះជូនកូនទៅសាលាហើយ ហើយត្រឡប់មកផ្ទះបងដែលស្នាក់នៅបណ្តោះអាសន្ន ដោយផ្ទះខ្លួននឹងធ្វើពុំទាន់រួច នៅក្បែរកន្លែងកើតហេតុ ក៏ត្រូវជនល្មើសមានគ្នា ០៤នាក់ មានឈ្មោះ[redacted]ឈ្មោះ[redacted],ឈ្មោះ:[redacted] ឈ្មោះ:[redacted]ដោយជិះម៉ូតូ០២គ្រឿង មួយគ្រឿងម៉ាកវ៉ានឌីឡាវ ពណ៌ក្រហម និងមួយគ្រឿងទៀតម៉ាកសង់ពណ៌ខ្មៅ មានកាំភ្លើងមួយដើមពុំស្គាល់ ម៉ាក ប្លន់កៀយកម៉ូតូតែម្តង ។ ពេលពួកវាយកម៉ូតូបាន ពួកវាក៏ជិះម៉ូតូវិលត្រឡប់ឡើងទៅផ្លូវលំលេខ២៧១ វិញ តែពុំបានឃើញបត់ស្តាំ ឬបត់ឆ្វេងឡើយ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ថាៈ ចោទប្រកាន់លើឈ្មោះ: [redacted]ភេទប្រុស អាយុ២៥ឆ្នាំ, ឈ្មោះ[redacted]ទប្រុស អាយុ២៣ឆ្នាំ, [redacted] ភេទប្រុស អាយុ២៥ឆ្នាំ, ឈ្មោះ[redacted]ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦, ៥៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៣១-ច- ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេចៈ

១-ផ្តន្ទាទោសឈ្មោះ ៖

[redacted]ភេទប្រុស អាយុ២៥ឆ្នាំ

[redacted]ភេទប្រុស អាយុ២៧ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៦ ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃអនុវត្តទោសតាមអំណាចសាលក្រមពីមុនៗចប់ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។



Scanned by CamScanner

២-ផ្តន្ទាទោសឈ្មោះ[redacted]ទប្រុស អាយុ២៣ ឆ្នាំ ដាក់ពន្ធនាគារកំណត់០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន១៨ ខែកក្កដា ឆ្នាំ២០០៥ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦ នៃច្បាប់ស្តីពី ស្ថានទម្ងន់ ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣-ផ្តន្ទាទោសឈ្មោ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារ កំណត់០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់ បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថាន ទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤-បង្គាប់ឱ្យឈ្មោះ[redacted] ឈ្មោ[redacted]ហៅ [redacted] ឈ្មោះ[redacted]និងឈ្មោះ[redacted]មគ្នាសងជូសជុលការខូចខាតចំនួន៩០០ដុល្លា (ប្រាំបួនរយដុល្លាអាមេរិក) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ះលេខ៤ ក្រុម២៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។ ក្នុងករណីរឹងរូសពុំព្រមសងត្រូវដាក់គុកបង្ខំដល់រូបរាងកាយ ដើម្បីទារប្រាក់ធនទណ្ឌនេះតាមមាត្រា៧ និង១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ។

៥-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ ឈ្មោះ[redacted] ឈ្មោ[redacted]និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ឈ្មោះ[redacted]ហៅ [redacted] ឈ្មោះ[redacted]និងដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤៦៧ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៦ របស់ឈ្មោះ[redacted]បណ្តឹងឧទ្ធរណ៍លេខ៣៩២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ឈ្មោ[redacted] បណ្តឹងឧទ្ធរណ៍លេខ៣២០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់ឈ្មោះ[redacted]ងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១៣១"ច" ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ គ្រប់ចំណុចនៃដីកាសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា៖

+បណ្តឹងឧទ្ធរណ៍របស់ឈ្មោ[redacted]ងឈ្មោះ [redacted]កជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយទាស់នឹងគតិច្បាប់។

+តម្កល់សាលក្រមលេខ១៣១"ច" ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការតាមច្បាប់តទៅ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៣២០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច៖

១-ក/ទទួលបណ្តឹងឧទ្ធរណ៍លេខ៤៦៧ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោ[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។



Scanned by CamScanner

ខ-ទទួលបណ្តឹងឧទ្ធរណ៍លេខ៣៩២ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] និងបណ្តឹងឧទ្ធរណ៍លេខ៣២០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់ជនជាប់ចោទឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១៣១ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ វៀរលែងតែចំណុចទី២ និងទី៣ ត្រូវបដិសេធ ហើយសម្រេចឡើងវិញថា ឱ្យឈ្មោះ [redacted] ភេទប្រុសអាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ២៥ រួចផុតពីបទចោទប្រកាន់ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងអោយលុបឈ្មោះ [redacted] ចេញពីចំណុចទី៤ ស្តីពីសំណងក្រៅពីនេះតម្កល់ទុកនៅដដែល។

៣-បង្គាប់ឱ្យដោះលែងឈ្មោះ [redacted] និងឈ្មោះ [redacted] ចេញពីមន្ទីរឃុំឃាំងភ្លាមបើឈ្មោះទាំងពីរនេះ មិនត្រូវបានឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ។

៤-បង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted]

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៦០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៣២០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ ដែលសម្រេចឱ្យឈ្មោះ [redacted] រួចខ្លួនពីបទ ប្លន់ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ នៅមុំវត្តដំបូកខ្ពស់ ផ្លូវលំ ក្រុម១០ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-បានឃើញសារណាក្នុងបណ្តឹងសាទុក្ខ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់ ឯកឧត្តមអគ្គព្រះរាជ អាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងត្រឹមត្រូវ តាមកំណត់ច្បាប់។

-បានឃើញលិខិតបង្គាប់ឲ្យធ្វើសារណា ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់ក្រឡាបញ្ជីតុលាការកំពូល ធ្វើឡើងត្រឹមត្រូវ តាមកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា៖

+បណ្តឹងសាទុក្ខរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិចារណាបានតាមមាត្រា១៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជំរះក្តី។

+មានភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] និង [redacted] ហៅ វ៉ាន់ ពីបទ៖ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ តាមមាត្រា៦, ៥៩ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល។



Scanned by CamScanner

+បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៨០-ខ- ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក [redacted] មធាវីការពារអោយជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការថា៖ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ កូនក្តីនាងខ្ញុំពុំបានធ្វើសកម្មភាពប្លន់ម៉ូតូគេទេ ព្រោះនៅថ្ងៃនោះកូនក្តីនាងខ្ញុំឈ្មោះ [redacted] ខេត្តកំពង់ចាម ដើម្បីមើលប្រពន្ធឆ្លងទន្លេ ចំណែកឈ្មោះ [redacted] នដែលស្គាល់ឈ្មោះ [redacted] ទ ហើយកាលថ្ងៃនោះកូនក្តីនាងខ្ញុំមិនបានប្លន់ជាមួយឈ្មោះ ជួន សុខខៃ ទេ ហើយក៏មិនបានទិញម៉ូតូពីឈ្មោះ ជួន សុខខៃ ដែរ។

សំណូមពរ៖ -សូមអោយកូនក្តីនាងខ្ញុំរួចផុតពីបទចោទ។

-មេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា៖ បណ្តឹងសាទុក្ខលេខ៦០ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ របស់ឯកឧត្តម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា៖ ការដែលសាលាឧទ្ធរណ៍សំរេចអោយឈ្មោះ [redacted] រួចផុតពីបទចោទ បទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិក្បាលទំនប់ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៨ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងអោយរួចផុតពីសំណងនេះ ដោយសំអាងទៅលើចម្លើយរបស់ឈ្មោះ ជួន សុខខៃ, ឌី ទីណា និង ព្រំ សុវណ្ណ នៅជាន់សាលាឧទ្ធរណ៍ថា ពេលប្រព្រឹត្តមានតែឈ្មោះ [redacted] ទ ជាអ្នកប្រព្រឹត្ត ការសំរេចនេះពុំត្រឹមត្រូវតាមគតិច្បាប់ទេ ពីព្រោះចម្លើយរបស់អ្នកទាំងបីឆ្លើយនៅអយ្យការ, នគរបាលយុត្តិធម៌ មានភាពស្របនឹងចម្លើយជនរងគ្រោះថា អ្នកទាំង [redacted] ចូលរួមប្រព្រឹត្តបទនេះពិតប្រាកដ ហើយការដោះសាររបស់អ្នកទាំងបីគ្មានភស្តុតាងបញ្ជាក់ទេ។

-យល់ឃើញថា៖ សាលដីកាសភាព្រហ្មទណ្ឌលេខ៨០-ខ- ចុះថ្ងៃទី០៣ ខែមេសាឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ទេ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ៦០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់។



Scanned by CamScanner

២-បដិសេធសាលដីកាសភាព្រហ្មទណ្ឌលេខ៨០-ខ- ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ត្រង់ចំណុចអោយឈ្មោះ [redacted] រួចផុតពីបទចោទ បទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២០៦ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសាជាថ្មីឡើងវិញ លើករណីឈ្មោះ [redacted]

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២
ជ.ប្រធានតុលាការកំពូល
អនុប្រធាន
[redacted]